ក្រសួងមុខងារសាធារណៈ

# សន្និបាតបូកសរុបលទ្ធផល ការងាររយៈពេលពីរឆ្នាំកន្លះ (ខែកញ្ញា ឆ្នាំ២០១៣ ដល់ ខែមីនា ឆ្នាំ២០១៦) និងលើកទិសដៅការងារ ឆ្នាំ២០១៦

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៦

ក្រសួងមុខងារសាធារណៈ

# បទបង្ហាញ

# ស្តីពី

# លទ្ធផលការងារ បញ្ហាប្រឈម

# និងទិសដៅការងារឆ្នាំ២០១៦

# របស់ក្រុមការងារយេនឌ័រ

បង្ហាញដោយ ឯកឧត្តម ដុក មុន្នី

អនុរដ្ឋលេខាធិការ និងជាប្រធាន

ក្រុមការងារយេនឌ័រ នៃក្រសួងមុខងារសាធារណៈ

# មាតិកា

១. លទ្ធផលការងារ

២. បញ្ហាប្រឈម

៣. ទិសដៅការងារឆ្នាំ២០១៦

## ១. លទ្ធផលការងារ

ក្រុមការងារយេនឌ័រ នៃក្រសួងមុខងារសាធារណៈ បានបំពេញតួនាទី ភារកិច្ច និងបេសកកម្មការងាររបស់ខ្លួនរយៈពេលពីរឆ្នាំកន្លះ(ខែកញ្ញា ឆ្នាំ២០១៣ ដល់ ខែមីនា ឆ្នាំ២០១៦)ទទួលបានលទ្ធផលការងារសំខាន់ៗ ដូចខាងក្រោម ៖

១-បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការបញ្ជ្រាបយេនឌ័រក្នុងវិស័យមុខងារសាធារណៈ ដល់មន្ត្រីរាជការស៊ីវិលក្របខ័ណ្ឌថ្មី ចំនួនពីរលើក មានសិក្ខាកាមចូលរួមសរុបចំនួន ២៤២នាក់ ក្នុងនោះស្ត្រីចំនួន ១៣៩នាក់ ដោយទទួលបានកិច្ចសហការពីគម្រោងភាពជាដៃគូដើម្បីសមធម៌យេនឌ័រក្រសួងកិច្ចការនារី និងការឧបត្ថម្ភគាំទ្ររបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ(UNDP) ។

# ១. លទ្ធផលការងារ

២-បានរៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពី ការពង្រឹងសមត្ថភាពជំនាញអ្នកសម្របសម្រួល មានសិក្ខាកាមចូលរួមសរុបចំនួន ៤៦នាក់ ក្នុងនោះស្រ្ដីចំនួន ៣៣នាក់ និងវគ្គបណ្ដុះបណ្ដាលស្ដីពីស្រ្ដីភាពជាអ្នកដឹកនាំក្នុងវិស័យមុខងារសាធារណៈ មានសិក្ខាកាមចូលរួមសរុបចំនួន ៤៨នាក់ ក្នុងនោះស្រ្ដីចំនួន ៣៥នាក់ ដោយទទួលបានកិច្ចសហការ និងការឧបត្ថម្ភគាំទ្ររបស់អង្គការ UN WOMEN ។

# ១. លទ្ធផលការងារ

៣-បានរៀបចំសិក្ខាសាលាចំនួន ០៦លើក រួមមាន ៖

-ការពិគ្រោះយោបល់លើសេចក្តីព្រាងផែនការយុទ្ធសាស្ត្របញ្ជ្រាបយេឌ័រក្នុងវិស័យមុខងារសាធារណៈ ដំណាក់កាលទី៣ ឆ្នាំ ២០១៤-២០១៨ មានអ្នកចូលរួមសរុបចំនួន ១៧០នាក់ ក្នុងនោះស្ត្រីចំនួន ៥១នាក់ ។

-ការផ្សព្វផ្សាយផែនការយុទ្ធសាស្ត្របញ្ជ្រាបយេឌ័រក្នុងវិស័យមុខងារសាធារណៈ ដំណាក់កាលទី៣ ឆ្នាំ២០១៤-២០១៨ មានអ្នកចូលរួមសរុបចំនួន ១១១នាក់ ក្នុងនោះស្ត្រីចំនួន ៤៦នាក់ ។

# ១. លទ្ធផលការងារ

-ការលើកកម្ពស់ស្រ្តីភាពជាអ្នកដឹកនាំក្នុងវិស័យមុខងារសាធារណៈ សមាសភាពចូលរួមសរុបមានចំនួន ១៨៧នាក់ ក្នុងនោះស្រ្តីមានចំនួន ១៣០នាក់ នៅសណ្ឋាគារហ៊ីម៉ាវ៉ារី ។

-ការពិគ្រោះយោបល់លើសេចក្តីព្រាងគោលនយោបាយនិងយុទ្ធសាស្រ្តជាតិលើកកម្ពស់ស្រ្តីភាពជាអ្នកដឹកនាំក្នុងវិស័យមុខងារសាធារណៈ ជាលើកដំបូង មានអ្នកចូលរួមសរុបចំនួន ៤៩ នាក់ ក្នុងនោះស្រ្តីចំនួន ៣០នាក់ នៅភោជនីយដ្ឋានទន្លេបាសាក់ ២ ។

-ការពិគ្រោះយោបល់លើសេចក្តីព្រាងគោលនយោបាយ និងយុទ្ធសាស្រ្តជាតិលើកកម្ពស់ស្រ្តីភាពជាអ្នកដឹកនាំក្នុងវិស័យមុខ

# ១. លទ្ធផលការងារ

ងារសាធារណៈ ជាលើកទី២ មានអ្នកចូលរួមសរុបចំនួន ៥៩នាក់ ក្នុងនោះស្ត្រីចំនួន ៣៣នាក់ នៅសណ្ឋាគារសាន់វេ ។

-ការពិគ្រោះយោបល់លើសេចក្តីព្រាងគោលនយោបាយ និងយុទ្ធសាស្ត្រជាតិលើកកម្ពស់ស្ត្រីភាពជាអ្នកដឹកនាំក្នុងវិស័យមុខងារសាធារណៈ ជាលើកទី៣ មានអ្នកចូលរួមសរុបចំនួន ៦៧នាក់ ក្នុងនោះស្ត្រីចំនួន ២៩នាក់ នៅសណ្ឋាគារសុខាភ្នំពេញ ។

# ភាគរយមន្ត្រីរាជការស៊ីវិលដែលមានមុខតំណែងចាប់ពីថ្នាក់ការិយាល័យតាមក្រុង/ស្រុក/ខណ្ឌ រហូតដល់ថ្នាក់អគ្គនាយក និងថ្នាក់ស្មើ បុរស ស្ត្រី ឆ្នាំ២០១៣-២០១៥



# ភាគរយមន្ត្រីរាជការស៊ីវិលសរុប បុរស ស្ត្រី ឆ្នាំ២០១៣-២០១៥



# ២. បញ្ហាប្រឈម

**ភាពជាអ្នកដឹកនាំ និងភាពជាតំណាងដោយស្មើភាពគ្នារបស់ស្ត្រី ក្នុងវិស័យមុខងារសាធារណៈ មានបញ្ហាប្រឈម ៖**

- សមត្ថភាពជំនាញបច្ចេកទេស និងភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅមានកម្រិត
-ខ្វះការលើកទឹកចិត្ត និងគាំទ្រពីបុរសជាថ្នាក់ដឹកនាំចំពោះមន្ត្រីជាស្ត្រី
-ខ្វះការគាំទ្រ លើកទឹកចិត្តពីគ្រួសាររបស់មន្ត្រីជាស្ត្រី
-មានការរើសអើងក្នុងចំណោមអ្នកដឹកនាំជាបុរស (ផ្នត់គំនិតសង្គម)
-មិនមានការផ្តល់ឱកាសពេញលេញជូនដល់ស្ត្រីពីសំណាក់គ្រួសារ និងសហគមន៍
-ការប្តេជ្ញាចិត្ត និងការតាំងចិត្តរបស់ស្ត្រីមួយចំនួននៅមានកម្រិត
-គោលការណ៍ណែនាំនៅក្នុងការតែងតាំងតាមរូបភាពបោះឆ្នោតជារបាំងដ៏ក្រាស់ឃ្មឹកប្រឆាំងវត្តមាននារី

# ២. បញ្ហាប្រឈម

**បញ្ហាប្រឈមរបស់ស្ត្រីដែលជាអ្នកធ្វើសេចក្តីសម្រេចចិត្ត**
**ក្នុងវិស័យមុខងារសាធារណៈ មានដូចខាងក្រោម ៖**

១-សមត្ថភាពរបស់ស្ត្រីនៅមានកម្រិត និងខ្វះការជំរុញពីក្រសួង/ស្ថាប័ន ក្នុងការបណ្តុះបណ្តាល

២-ខ្វះការគាំទ្រពីមជ្ឈដ្ឋានជុំវិញខ្លួនគាត់(គ្រួសារ ថ្នាក់ដឹកនាំសង្គម) និងខ្វះលទ្ធភាពទទួលបានព័ត៌មាន

៣-សម្លេងរបស់ស្ត្រីនៅមានចំនួនតិចនៅក្នុងក្រសួង/ស្ថាប័ន

៤-ផ្នត់គំនិត គឺឲ្យតម្លៃបុរសច្រើនជាងស្ត្រី

៥-ខ្វះភាពក្លាហាន(ឆន្ទៈ លទ្ធភាព សមត្ថភាព) និងកត្តាសេដ្ឋកិច្ច

# ៣. ទិសដៅការងារឆ្នាំ២០១៦

ប្រការសំខាន់បំផុត និងចំពោះមុខ ក្រុមការងារយេនឌ័រ នៃក្រសួងមុខងារសាធារណៈ ត្រូវបំពេញបេសកកម្មការងាររបស់ខ្លួន ដើម្បីបន្តអនុវត្តផែនការយុទ្ធសាស្រ្តបញ្ជ្រាបយេនឌ័រក្នុងវិស័យមុខងារសាធារណៈ ដំណាក់កាលទី៣ ឆ្នាំ២០១៤-២០១៨ ដោយមានទិសដៅការងារសំខាន់ៗ ដូចតទៅ ៖

-ត្រៀមបើកសិក្ខាសាលាពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍន៍អន្តរជាតិលើសេចក្តីព្រាងគោលនយោបាយ និងយុទ្ធសាស្រ្តជាតិលើកកម្ពស់ស្រ្តីភាពជាអ្នកដឹកនាំក្នុងវិស័យមុខងារសាធារណៈ ដើម្បីប្រមូលធាតុចូលសំខាន់ៗដូចជា មតិយោបល់ កង្វល់ ទស្សនៈ បញ្ហាប្រឈមរបស់មន្ត្រីរាជការស៊ីវិលជាស្រ្តី និងស្វែងរកដំណោះស្រាយ ។

## ៣. ទិសដៅការងារឆ្នាំ២០១៦

-ត្រៀមចុះផ្សព្វផ្សាយផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យមុខងារសាធារណៈ ដំណាក់កាលទី៣ ឆ្នាំ២០១៤-២០១៨ នៅថ្នាក់ក្រោមជាតិ ។

-ចុះបណ្តុះបណ្តាលការបញ្ជ្រាបយេនឌ័រក្នុងវិស័យមុខងារសាធារណៈ និងផ្សព្វផ្សាយ គោលការណ៍ ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងការលើកកម្ពស់ស្ត្រី ដើម្បីទទួលបានការធ្វើសេចក្តីសម្រេចចិត្តដល់គ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរ-អង្គភាព រាជធានី ខេត្ត ប្រសិនបើមានដៃគូអភិវឌ្ឍន៍ ។

-ចុះសិក្សាស្រាវជ្រាវអំពីស្ថានភាពពិត និងតម្រូវការរបស់មន្ត្រីរាជការស៊ីវិលជាស្ត្រីដែលមានមុខតំណែង ដើម្បីស្វែងយល់ពី

# ៣. ទិសដៅការងារឆ្នាំ២០១៦

បញ្ហាប្រឈម និងរកដំណោះស្រាយ ។

-ជំរុញការងារបណ្តុះបណ្តាលការបញ្ជ្រាបយេនឌ័រក្នុងវិស័យមុខងារសាធារណៈឲ្យមាន ប្រសិទ្ធភាព គ្រប់ក្រសួង-ស្ថាប័ន និងរាជធានី/ខេត្តផ្សេងទៀត ។

-តាមដានការអនុវត្តអំពី ការបញ្ជ្រាបយេនឌ័រក្នុងវិស័យមុខងារសាធារណៈ នៅតាម ក្រសួង-ស្ថាប័ន ។

-បន្តស្វែងរកដៃគូអភិវឌ្ឍន៍ជាមួយអង្គការជាតិ និងអង្គការអន្តរជាតិ ដើម្បីការងារ ទទួលបានលទ្ធផលល្អប្រសើរ ។

យើងរួមគ្នាគាំទ្រការលើកកម្ពស់សមភាពយេនឌ័រ

ក្នុងវិស័យមុខងារសាធារណៈ !

ជួយមន្ត្រីរាជការស៊ីវិលជាស្ត្រី គឺជួយខ្លួនឯង

និងសង្គមជាតិ !

សូមអរគុណ!